**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ: ៨០១
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណីលេខ: ០០១/២៣ "ធ"
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣
និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨០១ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

**លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល**

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**រវាងដើមចោទ:**

ឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ភេទស្រី កើតឆ្នាំ១៩៥៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ[redacted] ។

ដោយមានលោក [redacted] អត្តលេខ៩៨១ និងលោក [redacted] អត្តលេខ២៥៨០T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃក្រុមហ៊ុនមេធាវី [redacted] ដែលមានការិយាល័យ[redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**និងសហចុងចម្លើយ:**

១. ឈ្មោះ [redacted] សេងហុង ភេទប្រុស កើតឆ្នាំ១៩៧០ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២២០៤២១៤៨៧ មានអាសយដ្ឋាន[redacted] ។

២. ឈ្មោះ [redacted] សុខហ៊ាង ភេទស្រី កើតឆ្នាំ១៩៧៩ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៤៦៤២១១ មានអាសយដ្ឋាននៅ[redacted] ។

## អង្គហេតុ និងការអះអាងរបស់គូភាគី

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

ប្តឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖

១- បង្គាប់ឱ្យភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បង់ប្រាក់ដើមចំនួន ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន)ដុល្លារអាមេរិក មកភាគីដើមចោទឈ្មោះ [redacted] ឡាយខាន់ ។



Scanned with CamScanner

២- បង្គាប់ឱ្យភាគីសហចុងចម្លើយបង់ការប្រាក់ចំនួន ២០ ៧៤៦,៤៤ (ពីរម៉ឺនប្រាំពីរយសែសិបប្រាំមួយក្បៀសសែសិបបួន)ដុល្លារអាមេរិក ដែលគិតចាប់ពីខែមីនា ឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២២ មកឱ្យភាគីដើមចោទ ។

៣- បង្គាប់ឱ្យភាគីសហចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន)ដុល្លារអាមេរិក គិតចាប់ពីខែតុលា ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន ។

៤- បង្គាប់ឱ្យភាគីសហចុងចម្លើយសងការខូចខាត និងជម្ងឺចិត្តចំនួន ១០០(មួយរយ)លានរៀលឱ្យមកភាគីដើមចោទ ។

៥- បង្គាប់ឱ្យភាគីសហចុងចម្លើយសងថ្លៃសេវាកម្មផ្នែកច្បាប់ចំនួន ២០(ម្ភៃ)លានរៀល មកឱ្យភាគីដើមចោទ ។

៦- សាលក្រមប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី១ និងចំណុចទី២ ។

៧- ប្រាក់ប្រដាប់ក្ដីតុលាការ និងប្រាក់ពន្ធលើកម្មវត្ថុនៃពាក្យបណ្ដឹង ជាបន្ទុករបស់ភាគីសហចុងចម្លើយ។

**ខ. អង្គហេតុ និងចំណុចវិវាទ**

១. រឿងក្ដីនេះដើមចោទបានអះអាងថា៖ ខ្លួនសូមរក្សាការទាមទារដូចក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ និងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ដោយសុំតុលាការចេញសាលក្រម៖

១.បង្គាប់ឱ្យភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បង់ប្រាក់ដើមចំនួន ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន)ដុល្លារអាមេរិក មកភាគីដើមចោទឈ្មោះ [redacted] ឡាយខាន់ ។

២. បង្គាប់ឱ្យភាគីសហចុងចម្លើយបង់ការប្រាក់ចំនួន ២០ ៧៤៦,៤៤ (ពីរម៉ឺនប្រាំពីរយសែសិបប្រាំមួយក្បៀសសែសិបបួន)ដុល្លារអាមេរិក ដែលគិតចាប់ពីខែមីនា ឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២២ មកឱ្យភាគីដើមចោទ ។

៣.បង្គាប់ឱ្យភាគីសហចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន)ដុល្លារអាមេរិក គិតចាប់ពីខែតុលា ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន ។

៤.បង្គាប់ឱ្យភាគីសហចុងចម្លើយសងការខូចខាត និងជម្ងឺចិត្តចំនួន ១០០(មួយរយ)លានរៀលឱ្យមកភាគីដើមចោទ ។

៥.បង្គាប់ឱ្យភាគីសហចុងចម្លើយសងថ្លៃសេវាកម្មផ្នែកច្បាប់ចំនួន ២០ (ម្ភៃ) លានរៀល មកឱ្យភាគីដើមចោទ ។

៦.សាលក្រមប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី១ និងចំណុចទី២ ។

៧.ប្រាក់ប្រដាប់ក្ដីតុលាការ និងប្រាក់ពន្ធលើកម្មវត្ថុពាក្យបណ្ដឹងជាបន្ទុកភាគីសហចុងចម្លើយ។

ដោយហេតុថា៖ កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បានខ្ចីប្រាក់ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ពីភាគីដើមចោទ

ឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ដោយមានភ្ជាប់ការប្រាក់ចំនួន ២%(ពីរភាគរយ)ក្នុងមួយខែ រយៈពេល០៤ឆ្នាំ ដោយដាក់បញ្ចាំអចលនវត្ថុ (ដី និងផ្ទះ) មួយកន្លែង ទំហំសរុប៤៥៥ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានព្រំប្រទល់ខាងជើងទល់នឹង [redacted] ទុំ ខាងត្បូងទល់នឹងផ្លូវ ខាងកើតទល់នឹងផ្លូវ ខាងលិចទល់នឹង ផ្លូវរទេះ ដែលមានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ២៧៩/១៣ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់មេឃុំវិហារសួគ៌ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដោយដាក់បញ្ចាំអចលនវត្ថុ (ដី និងផ្ទះ) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បានខ្ចីប្រាក់ភាគីដើមចោទចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក បន្ថែមទៀតដោយដាក់បញ្ចាំប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២៦ ខែ០៧ ឆ្នាំ២០១៨ ម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] សេងហុងដើម្បីធានាលើការសងប្រាក់។

បន្ទាប់ពីចុះកិច្ចសន្យាខ្ចីប្រាក់ ទាំងពីរខាងលើ ភាគីសហចុងចម្លើយ ពុំបានអនុវត្តកាតព្វកិច្ចក្នុងការបង់ការប្រាក់ និងសងប្រាក់ដើមឱ្យគ្រប់ចំនួនមកឱ្យដើមចោទតាមកាលកំណត់នោះទេ។ ទើបភាគីដើមចោទបានធ្វើការដាស់តឿន ទៅភាគីសហចុងចម្លើយ ឱ្យសងប្រាក់តាមរយៈលិខិតដាស់តឿន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ និងលិខិតដាស់តឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។ ទោះបីភាគីដើមចោទបានធ្វើការដាស់តឿនឱ្យសងជាប្រាក់ម្ដងជាពីរដងក្ដី ប៉ុន្តែភាគីសហចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចក្នុងការសងប្រាក់។

២. រឿងក្ដីនេះសហចុងចម្លើយបានអះអាងថា៖ ចុងចម្លើយឈ្មោះ [redacted] សេងហុង និងឈ្មោះ [redacted] សុខហ៊ាង បានអវត្តមានដោយគ្មានមូលហេតុ ដោយតុលាការបានបញ្ជូនដីកាកោះ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ ទៅដល់ទីលំនៅរបស់សាមីខ្លួន និងបានផ្ដិតមេដៃទទួលត្រឹមត្រូវតាមនីតិវិធីច្បាប់រួចអស់ហើយ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ប៉ុន្តែមិនបានបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងកំណត់។

៣. អង្គហេតុដែលគ្មានវិវាទ

កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បានខ្ចីប្រាក់ចំនួន ៣០ ០០០(បីម៉ឺន)ដុល្លារអាមេរិក ពីភាគីដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ដោយបានភ្ជាប់ការប្រាក់ចំនួន២%(ពីរភាគរយ)ក្នុងមួយខែ ហើយភាគីសហចុងចម្លើយបានឯកភាពធ្វើការបង់រំលោះទាំងប្រាក់ដើម និងការប្រាក់ប្រចាំខែរយៈពេល ០៤ឆ្នាំ (ត្រឹមថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២២) ដោយដាក់បញ្ចាំអចលនវត្ថុ(ដី និងផ្ទះ) មួយកន្លែងទំហំសរុប ៤៥៥ ម៉ែត្រកាឡា មានទីតាំងស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានព្រំប្រទល់ខាងជើងទល់នឹង [redacted] ទុំ ខាងត្បូងទល់នឹងផ្លូវ ខាងកើតទល់នឹងផ្លូវ ខាងលិចទល់នឹងផ្លូវរទេះ ដែលមានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ ២៧៩/១៣ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់មេឃុំវិហារសួគ៌ ។

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងប្រពន្ធឈ្មោះ [redacted] សុខហ៊ាង បានខ្ចីប្រាក់ភាគីដើមចោទចំនួន ១០ ០០០(មួយម៉ឺន)ដុល្លារអាមេរិក បន្ថែមទៀតដោយដាក់បញ្ចាំប័ណ្ណសម្គាល់យានយន្តចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ ម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] សេងហុង ដើម្បីធានាលើការសងប្រាក់ ។



Scanned with CamScanner

៤. ចំណុចវិវាទ

១- តើសហចុងចម្លើយមានកាតព្វកិច្ចរួមគ្នាសងទៅដើមចោទនូវការប្រាក់ចំនួន ២% (ពីរភាគរយ) លើប្រាក់ដើម ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនពាន់ហុកសិបពីរក្បៀសដប់បួន) ដុល្លារអាមេរិក គិតចាប់ខែតុលា ឆ្នាំ២០២២ រហូតដល់សងគ្រប់ចំនួនដែរឬទេ?

២- តើសហចុងចម្លើយមានកាតព្វកិច្ចសងនូវការខូចខាត និងជម្ងឺចិត្តចំនួន ១០០(មួយរយ) លានរៀលឱ្យមកដើមចោទដែរឬទេ?

៣- តើសហចុងចម្លើយមានកាតព្វកិច្ចសងថ្លៃសេវាកម្មច្បាប់ចំនួន ២០ (ម្ភៃ) លានរៀល មកឱ្យដើមចោទដែរឬទេ?

៤- តើដើមចោទមានភាពចាំបាច់ក្នុងការប្រកាសអនុវត្តបណ្តោះអាសន្នលើសេចក្តីសម្រេចទី១ និងទី២ដែរឬទេ ?

**គ.ការពិនិត្យភស្តុតាង**

១. កិច្ចសន្យាខ្ចីប្រាក់ដោយដាក់បញ្ចាំអចលនវត្ថុ( ដី និងផ្ទះ )ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] សេងហុង ,ឈ្មោះ [redacted] សុខហ៊ាង និងឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ។(ថតចម្លង)

២. លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] សេងហុង , ឈ្មោះ [redacted] សុខហ៊ាង និងឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ។(ថតចម្លង)

៣. លិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ ២៧៩/១៣ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ចេញដោយរដ្ឋបាលឃុំវិហារសួគ៌ ។(ថតចម្លង)

៤. លិខិតព្រមព្រៀងគ្នាក្នុងការចងការប្រាក់ និងទទួលប្រាក់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ រវាងឈ្មោះ [redacted] ហុង ,ឈ្មោះ [redacted] ហ៊ាន និងឈ្មោះ [redacted] ឡាយខាន់ ។(ថតចម្លង)

៥. ប័ណ្ណសម្គាល់យានយន្តម៉ាក HYUNDAI MIGHTY ពាក់ស្លាកលេខ ភ្នំពេញ 3E-3923 ។ (ថតចម្លង)

៦. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៤២១៤៨៧(០១)របស់ឈ្មោះ [redacted] សេងហុង។ (ថតចម្លង)

៧. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៤៦៤២១១(០១)របស់ឈ្មោះ [redacted] សុខហ៊ាង។ (ថតចម្លង)

៨. លិខិតដាស់តឿនចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សេងហុង ,ឈ្មោះ [redacted] សុខហ៊ាង ។(ថតចម្លង)

៩. លិខិតដាស់តឿនចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ រវាងឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សេងហុង ,ឈ្មោះ [redacted] សុខហ៊ាង ។(ថតចម្លង)

១០. កិច្ចសន្យាទទួលស្គាល់ប្រាក់បំណុលចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សេងហុង ,ឈ្មោះ [redacted] សុខហ៊ាង។(ថតចម្លង)

## សំអាងហេតុ

១. ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ និងលិខិតព្រមព្រៀងប្រគល់-ទទួលប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់រវាងឈ្មោះ [redacted] សេងហុង , ឈ្មោះ [redacted] សុខហ៊ាង និងឈ្មោះ [redacted] ឡាយខាន់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ បានបញ្ជាក់ថាសហចុងចម្លើយពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន USD ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន) ដុល្លារអាមេរិក និងមានចែងអំពីចំនួនការប្រាក់ដែលត្រូវបង់ក្នុងមួយខែ ជារៀងរាល់ខែពិតប្រាកដមែន។ ដូច្នេះដោយផ្អែកតាមបញ្ញត្តិមាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា ចំពោះអង្គហេតុណាដែលភាគីបានសារភាពនៅចំពោះមុខតុលាការ ឬអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងឡើយ។ ចំពោះអង្គហេតុខាងលើភាគីសហចុងចម្លើយបានឆ្លើយសារភាពទទួលស្គាល់ទៅលើអត្ថិភាពនៃប្រាក់ដែលសហចុងចម្លើយបានខ្ចីពីដើមចោទតាមរយៈកិច្ចសន្យាខ្ចីប្រាក់ដោយដាក់បញ្ចាំអចលនវត្ថុ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពិតប្រាកដមែន ដូច្នេះតុលាការគប្បីមិនចាំបាច់ពិចារណាអំពីការខ្ចីប្រាក់ដោយផ្អែកតាមភស្តុតាងនោះទេ។

២. ក្រោយពីបានពិនិត្យទៅលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ និងលិខិតព្រមព្រៀងប្រគល់-ទទួលប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់រវាងឈ្មោះ [redacted] សេងហុង , ឈ្មោះ [redacted] សុខហ៊ាង និងឈ្មោះ [redacted] ឡាយខាន់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ផ្អែកតាមកិច្ចសន្យាខាងលើនេះ កិច្ចសន្យាខ្ចីប្រាក់នេះពិតជាកើតមានឡើងដោយស្របតាមឆន្ទៈរបស់ភាគីពិតប្រាកដមែន ដែលតាមបញ្ញត្តិមាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណីចែងថា កម្មវត្ថុនៃការសងការប្រាក់អាចយកមកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សរបាន ដែលចំណុចនេះគប្បីតុលាការពិចារណាតាមការទាមទាររបស់ដើមចោទ។

៣. ក្រោយពីបានពិនិត្យទៅលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ និងលិខិតព្រមព្រៀងប្រគល់-ទទួលប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់រវាងឈ្មោះ [redacted] សេងហុង , ឈ្មោះ [redacted] សុខហ៊ាង និងឈ្មោះ [redacted] ឡាយខាន់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឃើញថាចំពោះការទាមទារការប្រាក់ចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ ឬស្មើនឹងចំនួន ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំនេះ ពុំផ្ទុយនឹងបទបញ្ញត្តិនៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវកម្រិត និងបញ្ញត្តិមាត្រា៥៨៤ មាត្រា៥៩១ នៃក្រមរដ្ឋប្បវេណីឡើយ។ តាមបញ្ញត្តិមាត្រា៥៨៤ បានចែងថា "អត្រាការប្រាក់អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬដោយការព្រមព្រៀងរបស់ភាគី" ហើយដោយផ្អែកតាមបញ្ញត្តិមាត្រា៥៩១ កថាខណ្ឌទី២ ចែងថា "អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់"។ ភ្ជាប់ជាមួយគ្នានេះ ផ្អែកតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការកម្រិតអត្រាការប្រាក់បានចែងថា អត្រាការប្រាក់ដែលត្រូវបានកម្រិត ត្រូវបានកំណត់មិនឱ្យលើសពី ១៨ភាគរយក្នុងមួយឆ្នាំនោះទេ។ ដោយឡែក ចំពោះអត្រាការប្រាក់ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ (ការប្រាក់យឺតយ៉ាវ) ត្រូវបានកំណត់មិនឱ្យលើសពី ១,៥ ដងនៃអត្រាការប្រាក់ដែលកម្រិតត្រឹម ១៨ (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ ឬស្មើនឹង ២៧ (ម្ភៃប្រាំពីរ) ភាគរយក្នុងមួយឆ្នាំនោះឡើយ។ ដូច្នេះហើយ បើផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ដោយដាក់បញ្ចាំអចលនវត្ថុ (ដី

និងផ្ទះ) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមចោទ និងសហចុងចម្លើយ ត្រង់ចំណុចប្រការ ៣ បានចែងអំពីការកំណត់ជាមុននូវសំណងការខូចខាតក្នុងការមិនបង់ប្រាក់ដើម និងការប្រាក់ ដោយបានកំណត់យកការពិន័យជាប្រាក់ចំនួន ២ (ពីរ)ភាគរយនៃប្រាក់ដែលត្រូវបង់ប្រចាំខែ គិតរហូតដល់ពេលដែលភាគីសហចុងចម្លើយបានបង់ការប្រាក់មកឱ្យភាគីដើមចោទគ្រប់ចំនួន ដែលឃើញថាឃ្លានេះត្រង់ចំណុចនេះគឺជាការកំណត់នូវអត្រាការប្រាក់យឺតយ៉ាវ ឬការកំណត់ទុកជាមុននូវសំណងការខូចខាត គប្បីតុលាការពិចារណាអំពីការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។

៤. ផ្អែកតាមការអះអាង និងសេចក្តីថ្លែងការណ៍របស់ដើមចោទពាក់ព័ន្ធនឹងការទាមទារប្រាក់សំណងជម្ងឺចិត្ត និងការខូចខាតចំនួន១០០ (មួយរយ) លានរៀល តុលាការពិនិត្យឃើញថាភាគីសហចុងចម្លើយពិតជាបានបំពានកាតព្វកិច្ចដោយមិនបានធ្វើបង់ប្រាក់ដើម និងការប្រាក់ទៅដើមចោទទៅតាមកាលកំណត់ពិតមែន ហើយបើទោះជាដើមចោទបានព្យាយាមធ្វើការដាស់តឿនទៅកាន់សហចុងចម្លើយឱ្យសងប្រាក់មកកាន់ដើមចោទតាមរយៈលិខិតដាស់តឿនយ៉ាងណាក្តី ក៏ភាគីសហចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចក្នុងការសងប្រាក់ទៅឱ្យដើមចោទដដែល ដែលសកម្មភាពនេះពិតជាបានបង្កាញពីការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ភាគីដើមចោទ ដែលតុលាការគប្បីពិចារណាទៅលើការទាមទារខាងលើ ក៏ប៉ុន្តែដោយសារដើមចោទពុំមានដាក់ភស្តុតាងបញ្ជាក់ឱ្យបានច្បាស់លាស់ពីទំហំនៃការខូចខាតទេនោះ គប្បីតុលាការពិចារណាឱ្យសំណងលើការខូចខាតនេះតាមគោលការណ៍សមធម៌។

៥. ដើមចោទទាមទារឱ្យអនុវត្តបណ្តោះអាសន្នចំពោះចំណុចទី១ និងចំណុចទី២ ដោយតុលាការពិនិត្យឃើញថា ការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងនេះ គឺជាការទាមទារជាប្រាក់ និងដោយពិចារណាឃើញថាមានភាពចាំបាច់គ្រប់គ្រាន់ក្នុងការប្រកាសអនុវត្តបណ្តោះអាសន្ន ដូច្នេះគប្បីតុលាការពិចារណាទៅលើការប្រកាសឱ្យអនុវត្តបណ្តោះអាសន្នទៅលើចំណុចទី១ និងចំណុចទី២ តាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦. ផ្អែកតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ភាគីចាញ់ក្តី ។

## ហេតុដូច្នេះ តុលាការធ្វើការវិនិច្ឆ័យដូចខាងក្រោម ៖

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងឈ្មោះ [redacted] សុខហ៊ាង រួមគ្នាសងប្រាក់ដើមសរុបចំនួន USD ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន) ដុល្លារអាមេរិកទៅឱ្យដើមចោទ។

២. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងឈ្មោះ [redacted] សុខហ៊ាង រួមគ្នាសងការប្រាក់ចំនួន ២០ ៧៤៦,៤៤(ពីរម៉ឺនប្រាំពីររយសែសិបប្រាំមួយក្បៀសសែសិបបួន)ដុល្លារអាមេរិក គិតចាប់ពីខែមីនា ឆ្នាំ២០២០ ដល់ខែកញ្ញា ឆ្នាំ២០២២ មកឱ្យភាគីដើមចោទ ការទាមទារលើសពីនេះត្រូវច្រានចោល។

៣. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងឈ្មោះ [redacted] សុខហ៊ាង រួមគ្នាបង់ប្រាក់សំណងការប្រាក់យឺតយ៉ាវ ទៅឱ្យដើមចោទចំនួន ២%(ពីរ) ភាគរយ ក្នុងមួយខែ ទៅលើប្រាក់ដើម



Scanned with CamScanner

ចំនួន USD ៣៣ ៤៦២,១៤ (បីម៉ឺនបីពាន់បួនរយហុកសិបពីរក្បៀសដប់បួន) ដុល្លារអាមេរិក គិតចាប់ពីខែតុលា ឆ្នាំ២០២២ រហូតដល់សងប្រាក់ដើមគ្រប់ចំនួនឱ្យដើមចោទ ការទាមទារលើសពីនេះត្រូវច្រានចោល។

៤. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សេងហុង និងឈ្មោះ [redacted] សុខហ៊ាង សងថ្លៃសេវាកម្មផ្នែកច្បាប់ចំនួន ៤(បួន)លានរៀល មកឱ្យដើមចោទ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៥. ប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី១ និងចំណុចទី២ នៃសេចក្ដីសម្រេចបញ្ចប់ ការទាមទារលើសពីនេះច្រានចោល។

៦. ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទនិងកំបាំងមុខសហចុងចម្លើយ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ។

*ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

ហត្ថលេខា និងត្រា

[redacted]

---

*"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"*

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ខេត្តកណ្ដាល, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]